## អរិយធម៌ អាណាតូលីយ៉ា ឬ ហេតធី ( Anatolia or Hittite civilization )

អាណាតូលីយ៉ា (Anatolia) ឬបច្ចុប្បន្នហៅថា Asia Minor គឺជាឧបទ្វីបដ៏ធំមួយនៅអាស៊ីខាងលិច និងអ៊ឺរ៉ុប ។ បច្ចុប្បន្នគឺជាផ្នែកធំមួយនៃប្រទេសទួគី ។ នៅក្នុងប្រវត្តិនៃតំបន់អាណាតូលីយ៉ានេះបានកកើតឡើងនៅពេលដែលជនជាតិ ហេតធី (Hittite) បានមកតាំងទីនៅតំបន់នេះ ក្នុងអំឡុងឆ្នាំ ១៦០០មុនគ.ស. បន្តបន្ទាប់មកបានក្លាយជាអាណាចក្រ Hittite។ អរិយធម៌ និងអាណាចក្រនេះទទួលឥទ្ធិពលស្ទើតែទាំងស្រុងពីអរិយធម៌មេសូប៉ូតាមី ទាំងនយោបាយ សាសនា ទំនៀមទម្លាប់ជាដើម។[១]

នៅដើមស.វ.ទី ១៩ អ្នកស្រាវជ្រាវបុរាណវិទ្យា មកពីវិទ្យាស្ថានស្រាជ្រាវជ្រាវជាតិនៃប្រទេស ធែកបានរកឃើញ និងធ្វើកំណាយនៅទីក្រុងបុរាណមួយកន្លែងឈ្មោះ Hattusha ដែលដឹងថា ជារាជធានីនៃ អាណាចក្រ ហេតធី និងអរិយធម៌អាណាតូលីយ៉ា។[២] បច្ចុប្បន្នទីក្រុងនេះមានទីតាំងនៅស្រុក Boğazkale នៃខេត្ត Çorum ក្នុងប្រទេសទួគី។ ទីក្រុងនេះកសាងនៅលើ ភ្នំធម្មតាមួយនៅភាគខាងជើងនៃតំបន់ភ្នំ Anatolian។ ទីក្រុងជាបណ្តុំនៃសំណង់ស្ថាបត្យកម្មដ៏សំខាន់ក្នុងអរិយធម៌ អាណាតូលីយ៉ា និងមានឆ្លាក់រូបនៅជ្រលងភ្នំធំសម្រាប់ធ្វើជាក្លោងទ្វារចូលក្នុងវាំង រួមមានទាំងកំពែងអំពីថ្ម មានប្រវែងជាង៨ម៉ែត្រ ។ ទីក្រុងនេះបានបែងចែកជាផ្នែកលើ និងផ្នែកក្រោម ដោយផ្នែកខាងលើជាតំបន់សំខាន់ៗរួមមានរាជវាំង ប្រាសាទសម្រាប់អធិទេព រីឯផ្នែកខាងក្រោមជាកន្លែងសម្រាប់រស់នៅ។ ប្រាសាទសំខាន់ជាងគេនៅក្នុងទីក្រុង Hattusha ស្ថិតនៅក្នុងស.វ.ទី១៣មុនគ.ស. និងមានរូបចម្លាក់ អធិទេពនៅក្លោងទ្វារដែរ។ សិល្បៈនៃការឆ្លាក់ និងរបៀបរៀបចំគឺទទួលឥទ្ធិពល

---

[១] https://www.britannica.com/place/Mesopotamia-historical-region-Asia/The-character-and-influence-of-ancient-Mesopotamia

[២] https://www.khanacademy.org/humanities/world-history/world-history-beginnings/ancient-egypt-hittites/a/the-hittites

អត្ថបទដោយ៖ អេង តុលា

ពីអរិយធម៌មេសូប៉ូតាមី។[៣] ជាពិសេសចម្លាក់រូបលើជញ្ជាំងថ្មដែលឃើញមានរូបខ្លួនជាសត្វតោ និងក្បាលជាសត្វឥន្ទ្រី ដែលហៅថា Griffin។

ក្រៅពីរាជធានី Hattusha អ្នកស្រាវជ្រាវបានរកឃើញស្ថានីយ៍សំខាន់ជាច្រើនផ្សេងទៀត ជាពិសេស ស្ថានីយ៍ត្រូយ (Archaeological Site of Troy)។ ស្ថានីយនេះត្រូវបានធ្វើកំណាយដំបូងនៅឆ្នាំ១៨៧០ដោយអ្នកបុរាណវិទូ ឈ្មោះ Heinrich Schliemann។ តាមរយៈការធ្វើកំណាយជាច្រើននៅស្ថានីយ៍នេះ បានបង្ហាញថាទីនេះមានអាយុកាលប្រហែល ៤០០០ឆ្នាំ និងទីនេះត្រូវបានគ្រប់គ្រងដោយអរិយធម៌អាណាតូលីយ៉ា និងក៏ជាគឺជាកស្តុតាងដ៏សំខាន់មួយនៃទំនាក់ទំនងរវាងអរិយធម៌អាណាតូលីយ៉ា និងបណ្តាអរិយធម៌នៅតំបន់មេឌីទែរ៉ាណេ។

ជនជាតិ Hittite បុរាណមានជឿលើ អទិទេព Ahura Mazda ឬហៅថា សាសនា Zoroastrianism ដែលទទួលឥទ្ធិពលពីអរិយធម៌មេសូប៉ូតាមី ។

តាមរយៈការសិក្សាបុរាណលោហៈវិទ្យា អំពីវត្ថុសិល្បៈអំពីលោហធាតុជាពិសេសឧបករណ៍ដែក អ្នកស្រាវជ្រាវបានបង្ហាញថា ជនជាតិHittite ចេះវិធីសាស្រ្តចម្រាញ់រ៉ែដែក និងស្មិតទៅជាឧបករណ៍ដែកមុនគេ ប្រហែល ១៥០០ឆ្នាំមុនគ.ស. ។ ទោះបីជាយ៉ាងណាវត្ថុសិល្បៈនៃអរិយធម៌នេះបានបង្ហាញថា ហេតធី ឬ អាណាតូលីយ៉ា ជាអរិយធម៌ដែលចាស់ជាងគេនៅក្នុងតំបន់ Asia Minor[៤] និងបង្ហាញវិសាលភាពទឹកដីនៃអរិយធម៌នេះដោយគ្រប់គ្រងនៅតំបន់ អាណាតូលីយ៉ា ទាំងមូល ។

អ្នកស្រាវជ្រាវពុំដឹងអំពីមូលហេតុច្បាស់លាស់នៃការដួលរលំនៃអរិយធម៌ អាណាតូលីយ៉ា ឬ អាណាចក្រ ហេតធីនោះទេ ប៉ុន្តែប្រហែលមកពីការឈ្លានពានពីជនជាតិផ្សេងៗ

[៣] https://whc.unesco.org/en/list/377/

[៤] https://www.researchgate.net/publication/329281294_History_of_Anatolia_Through_Readings_For_Tour_Guiding_Students

អត្ថបទដោយ៖ អេង តុលា

ដែលរីកចម្រើនជាងអាណាចក្រខ្លួន និងមានកត្តាផ្សេងៗដែលធ្វើឲ្យអរិយធម៌នេះចុះខ្សោយ និងដួលរលំ។[៥]

សរុបមកអរិយធម៌នេះជាអរិយធម៌ដែលមានបច្ចេកទេសក្នុងការចម្រាញ់រ៉ែ ដែក និងបច្ចេកទេសផលិតវត្ថុសិល្បៈអំពីលោហធាតុដ៏ចំណាស់មួយ។ តាមរយៈវត្ថុទាំងនោះ បានបង្ហាញថាអរិយធម៌នេះមានឥទ្ធិពលរបស់ខ្លួនរយៈពេល៥០០ឆ្នាំ ពោលឆ្នាំ១៦០០-១១៨០មុនគ.ស.៕




រូបលេខ១៖ ផែនទីនៃអាណាចក្រ ហេតធី ឬអរិយធម៌អាណាតូរ៉យ៉ា

ប្រភព៖ Khan academy

[៥] https://www.worldhistory.org/article/1580/lost-civilisations-of-anatolia-gobekli-tepe/



រូបលេខ២-៣៖ ផ្នែកខាងលើនៃទីក្រុង Hattusha  និងរូបទី៣ ក្លោងទ្វារចូលទីក្រុង

ប្រភព៖UNESCO



អត្ថបទដោយ៖ អេង តុលា



រូបលេខ២-៥៖ រូបចម្លាក់នៅតាមជ្រលងភ្នំ ក្នុងទីក្រុង Hattusha

ប្រភព៖UNESCO





រូបលេខ២៦ ៖ ស្ថានីយបុរាណវិទ្យា Troy និងរូបលេខ២៧ សសរមានរូបរបស់អធិទេព Anu
ប្រភព៖UNESCO



# ឯកសារយោង

https://www.britannica.com/place/Mesopotamia-historical-region-Asia/The-character-and-influence-of-ancient-Mesopotamia

https://www.khanacademy.org/humanities/world-history/world-history-beginnings/ancient-egypt-hittites/a/the-hittites

https://whc.unesco.org/en/list/377/

https://www.researchgate.net/publication/329281294_History_of_Anatolia_Through_Readings_For_Tour_Guiding_Students

អរិយធម៌ខ្មែរ KHMER CIVILIZATION

អត្ថបទដោយៈ អេង តុលា